# អែលឌើរហ្គុងទៅទស្សនកិច្ច ប្រទេសអ៊ីតាលី









អែលឌើរ ជែរីត ដ័បុលយូ ហ្គុង និង ស៊ិស្ទើរ ស៊ូសាន ហ្គុង បានធ្វើដំណើរទៅប្រទេសអ៊ីតាលី ពេលព្រះវិហារបរិសុទ្ធរ៉ូម អ៊ីតាលី បានឧទ្ទិសឆ្លង ។ វាគឺជាព្រះវិហារបរិសុទ្ធទីមួយដែលត្រូវបានសាងសង់នៅកន្លែងដែលពួកសាវករបស់ព្រះយេស៊ូវបានបង្រៀននៅក្នុងជំនាន់ព្រះគម្ពីរប៊ីប !



កុមារទាំងនេះបានមកជាមួយគ្រួសាររបស់ពួកគេ ដើម្បីស្ដាប់ប្រធាន រ័សុល អិម ណិលសុន ឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធថ្មី ។ នៅពេលពួកគេធំឡើង ពួកគេអាចធ្វើពិធីបុណ្យជ្រមុជទឹកនៅព្រះវិហារបរិសុទ្ធ !



អែលឌើរហ្គុង គណៈប្រធានទីមួយ និងពួកសាវកដទៃទៀតបានថតរូបនៅមជ្ឈមណ្ឌលអ្នកទស្សនាថ្មី ។ ពួកលោកបានឈរនៅពីមុខរូបសំណាកព្រះយេស៊ូវគ្រីស្ទ និងពួកសាវករបស់ទ្រង់ ។

សូមរកមើលវីដេអូ « ដកស្រង់មកពី ‹ ព្រះគ្រីស្ទមានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក › » នៅគេហទំព័រ ChurchofJesusChrist.org ។